# ស្វែងរកសេចក្តីអំណរក្នុងការបម្រើ

អែលឌើរ អិម រ័សុល បាឡឺដ
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*ចូរយើងបង្ហាញក្តីស្រឡាញ់ និងការដឹងគុណរបស់យើងចំពោះការលះបង់ដ៏ធួនរបស់ព្រះអង្គសង្គ្រោះ តាមរយៈទង្វើនៃការបម្រើដ៏សាមញ្ញ និងមានក្តីសន្តោសរបស់យើង ។*

បងប្អូនប្រុសស្រី ខ្ញុំសង្ឃឹមថា អ្នកទាំងឡាយដែលកំពុងមកលេងទីក្រុងសលត៍ លេក នឹងឆ្លៀតឱកាសមើលផ្កានានិទាឃៈរដូវដែលមានពណ៌ និងក្លិនចម្រុះដុះនៅជុំវិញព្រះវិហារបរិសុទ្ធសលត៍ លេក ។

និទាឃៈរដូវ នាំមកជាថ្មីនូវពន្លឺ និងជីវិត ---តាមរយៈវដ្តនៃរដូវកាល វារំឭកយើងពីជីវិត ការលះបង់ និងការរស់ឡើងវិញនៃព្រះប្រោសលោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ ត្បិត « គ្រប់ការណ៍ទាំងអស់ធ្វើទីបន្ទាល់ពីទ្រង់ » ( ម៉ូសេ 6:63 ) ។

ផ្ទុយទៅនឹងទិដ្ឋភាពដ៏ស្រស់ស្អាត នៃនិទាឃៈរដូវ និងនិមិត្តសញ្ញានៃក្តីសង្ឃឹមរបស់វា នោះមាននូវពិភពលោកមួយដែលពុំប្រាកដ ស្មុគស្មាញ និងច្របូកច្របល់ ។ តម្រូវការនៃជីវិតប្រចាំថ្ងៃគឺ---ការអប់រំ ការងារ ការចិញ្ចឹមកូន ការគ្រប់គ្រង និងការបម្រើក្នុងសាសនាចក្រ សកម្មភាពខាងលោកិយ និងសូម្បីតែជាការឈឺចាប់ និងទុក្ខព្រួយនៃជំងឺ និងសោកនាដកម្មផ្សេងៗដែលមិនបានរំពឹងទុក---អាចធ្វើឲ្យយើងទន់ខ្សោយ ។ តើយើងអាចរំដោះខ្លួនយើងចេញពីសំណាញ់ឧបសគ្គដ៏ជំពាក់ជំពិន និងភាពមិនច្បាស់លាស់នេះ ដើម្បីរកសេចក្តីសុខសាន្តនៃគំនិត និងសុភមង្គលបានដោយរបៀបណាទៅ ?

ជាញឹកញាប់ យើងគឺដូចជាពាណិជ្ជករវ័យក្មេងពីទីក្រុងបូស្តុន ដែលក្នុងឆ្នាំ 1849 ដូចដែលដំណើររឿងរ៉ាយរ៉ាប់ នោះបានចូលរួមយ៉ាងមោះមុតក្នុងការជីកមាសនៅរដ្ឋកាលីហ្វ័រញ៉ា ។ គាត់បានលក់ទ្រព្យសម្បត្តិទាំងអស់របស់គាត់ ដើម្បីស្វែងរកសំណាងរបស់គាត់នៅក្នុងទន្លេកាលីហ្វ័រញ៉ា ដែលគេប្រាប់គាត់ថាទន្លេនោះមានពោរពេញទៅដោយដុំមាសធំៗជាច្រើន ដែលពិបាកសម្រាប់មនុស្សម្នាក់នឹងលើកវា ។

ពីមួយថ្ងៃទៅមួយថ្ងៃដោយមិនចេះចប់ យុវជននោះយកខ្ទះរែងមាសរបស់គាត់ចូកចូលទៅក្នុងទន្លេ ហើយលើកឡើងទទេ ។ រង្វាន់របស់គាត់គឺគ្រាន់តែជាដុំថ្មមួយពំនូកប៉ុណ្ណោះ ។ ដោយអស់សង្ឃឹម និងខកចិត្ត គាត់សម្រេចថានឹងឈប់ទៅហើយ រហូតទាល់តែមានអ្នករែងមាសវ័យចំណាស់ និងមានបទពិសោធន៍ម្នាក់ បាននិយាយទៅកាន់គាត់ថា « នោះជាថ្មមួយពំនូកដែលឯងរកបានហើយ កូនប្រុសខ្ញុំអើយ » ។

យុវជននោះឆ្លើយតបថា « គ្មានមាសនៅទីនេះទេ ខ្ញុំនឹងត្រឡប់ទៅផ្ទះវិញហើយ » ។

ដោយដើរទៅកាន់ពំនូកថ្មនោះ អ្នករែងមាសចំណាស់បាននិយាយថា « អូ មានមាសតើ ។ ឯងគ្រាន់តែមិនដឹងកន្លែងរកវាប៉ុណ្ណោះ » ។ គាត់បានរើសថ្មពីរដុំឡើង ហើយគោះវាជាមួយគ្នា ។ ថ្មមួយដុំបែក ហើយចេញនូវបំណែកមាសតូចៗ ជះពន្លឺនៅក្រោមពន្លឺព្រះអាទិត្យ ។

ដោយកត់សម្គាល់ពីថង់ស្បែកដែលក្រវាត់នៅនឹងចង្កេះរបស់អ្នករែងមាសនោះ យុវជននោះបាននិយាយថា « ខ្ញុំកំពុងរកមើលដុំមាសដូចនៅក្នុងថង់របស់ពូហ្នឹង មិនមែនបំណែកមាសតូចៗនេះទេ » ។

អ្នករែងមាសវ័យចំណាស់ ហុចថង់គាត់ឲ្យយុវជននោះ ដែលបានសម្លឹងមើលទៅខាងក្នុង ដោយរំពឹងថាគេនឹងឃើញដុំមាសធំៗជាច្រើន ។ គេស្រឡាំងកាំង ដោយឃើញថាក្នុងថង់នោះពេញទៅដោយបំណែកមាសតូចៗរាប់ពាន់បំណែក ។

អ្នករែងមាសវ័យចំណាស់បាននិយាយថា « កូនប្រុស វាហាក់ដូចជាឯងកំពុងតែរវល់ខ្លាំងណាស់ក្នុងការរកមើលដុំមាសធំៗ ដែលធ្វើឲ្យឯងខកខានមិនបានបំពេញថង់របស់ឯងជាមួយនឹងបំណែកមាសតូចៗដ៏មានតម្លៃទាំងនេះ ។ ការប្រមូលបំណែកមាសតូចៗទាំងនេះដោយការអត់ធ្មត់ បាននាំឲ្យខ្ញុំមានទ្រព្យសម្បត្តិជាច្រើន ។

រឿងនេះបានបង្ហាញពីសេចក្ដីពិតខាងវិញ្ញាណដែលអាលម៉ា បានបង្រៀនកូនរបស់គាត់ ហេលេមិនថា ៖ « ដោយកិច្ចការតូចតាច និងងាយ ទើបនាំឲ្យកើតកិច្ចការធំៗបាន ... ហើយដោយមធ្យោបាយដ៏សែនតូច នោះព្រះអម្ចាស់ ទ្រង់ ...នាំមកនូវការសង្គ្រោះដល់មនុស្សជាច្រើន » ។ ( អាលម៉ា 37:6—7 )

បងប្អូនប្រុសស្រី ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ គឺសាមញ្ញ មិនថាយើងព្យាយាមយ៉ាងណា ដើម្បីឲ្យវាស្មុគស្មាញនោះទេ ។ យើងគួរតែព្យាយាមរក្សាជីវិតរបស់យើងឲ្យសាមញ្ញដែរ រំដោះខ្លួនចេញពីឥទ្ធិពលខាងក្រៅ ហើយផ្ដោតទៅអ្វីដែលសំខាន់បំផុត ។

តើអ្វីជាការណ៍ដ៏មានតម្លៃ និងសាមញ្ញនៃដំណឹងល្អ ដែលនាំមកនូវភាពច្បាស់លាស់ និងគោលបំណងសម្រាប់ជីវិតរបស់យើង ? តើអ្វីជាបំណែកតូចៗនៃដំណឹងល្អ ដែលយើងប្រមូលដោយអត់ធ្មត់ អស់មួយជីវិតរបស់យើង ដែលនឹងផ្ដល់រង្វាន់ដល់យើង ជាមួយនឹងសម្បត្តិដ៏ប្រពៃបំផុត---គឺជាអំណោយដ៏មានតម្លៃនៃជីវិតដ៏នៅអស់កល្បជានិច្ច ?

ខ្ញុំជឿថា មានអ្វីមួយដែលសាមញ្ញ ប៉ុន្តែអស្ចារ្យ---គឺវិសេសបំផុត---គឺជាគោលការណ៍ដែលនៅជុំវិញភាពពេញលេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនោះឯង ។ បើយើងឱបក្រសោបដោយអស់ពីដួងចិត្ត និងធ្វើឲ្យគោលការណ៍នេះ ក្លាយជាការផ្ដោតនៃជីវិតរបស់យើង នោះវានឹងធ្វើឲ្យយើងបានបរិសុទ្ធ និងល្អឥតខ្ចោះ ដើម្បីយើងអាចរស់នៅក្នុងវត្តមាននៃព្រះម្ដងទៀត ។

ព្រះអង្គសង្គ្រោះបានមានបន្ទូលពីគោលការណ៍នេះ កាលទ្រង់បានឆ្លើយតបទៅពួកផារិស៊ីម្នាក់ដែលបានសួរថា « លោកគ្រូ ក្នុងបណ្ដាក្រឹត្យវិន័យ តើបញ្ញត្តណាដែលយ៉ាងសំខាន់បំផុត ? »

« នោះព្រះយេស៊ូវឆ្លើយថា ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង ។

« នេះជាបញ្ញត្តយ៉ាងសំខាន់ទីមួយ ។
« ហើយបញ្ញត្តទីពីរ ក៏បែបដូចគ្នាដែរ គឺថា ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង » ( ម៉ាថាយ 22:36—40 ) ។

មានតែនៅពេលយើងស្រឡាញ់ព្រះ និងព្រះយេស៊ូវគ្រីស្ទ អស់ពីចិត្ត អស់ពីព្រលឹង និងអស់ពីគំនិត ប៉ុណ្ណោះ ដែលយើងអាចចែកចាយក្ដីស្រឡាញ់នេះ ជាមួយនឹងអ្នកជិតខាងរបស់យើង តាមរយៈទង្វើចិត្តល្អ និងការបម្រើ---តាមរបៀបដែលព្រះអង្គសង្គ្រោះនឹងស្រឡាញ់ និងបម្រើយើងទាំងអស់គ្នា បើទ្រង់នៅក្នុងចំណោមយើងសព្វថ្ងៃនេះ ។

ពេលដែលក្ដីស្រឡាញ់ដ៏បរិសុទ្ធនៃព្រះគ្រីស្ទ ---ឬសេចក្ដីសប្បុរស ---ហ៊ុំព័ទ្ធយើង នោះយើងគិត មានអារម្មណ៍ និងធ្វើ កាន់តែដូចជាព្រះវរបិតា និងព្រះយេស៊ូវ គិត និងមានអារម្មណ៍ និងធ្វើ ។ ការជំរុញ និងបំណងប្រាថ្នាចេញពីដួងចិត្តរបស់យើង គឺដូចជារបស់ព្រះអង្គសង្គ្រោះដែរ ។ ទ្រង់បានចែកចាយបំណងរបស់ទ្រង់ជាមួយនឹងសាវករបស់ទ្រង់នៅល្ងាចមុនថ្ងៃឆ្កាងទ្រង់ ៖

ទ្រង់បានមានបន្ទូលថា ៖ « ខ្ញុំឲ្យសេចក្ដីបញ្ញត្តថ្មីមួយដល់អ្នករាល់គ្នា គឺឲ្យស្រឡាញ់គ្នាទៅវិញទៅមក ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ...។

« គេនឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ដោយសារសេចក្ដីនេះឯង » ( យ៉ូហាន 13:34—35 ) ។

ក្ដីស្រឡាញ់ដែលព្រះអង្គសង្គ្រោះបានពណ៌នានោះ គឺជាក្ដីស្រឡាញ់ដ៏សកម្ម ។ វាមិនត្រូវបានបង្ហាញតាមរយៈកិច្ចការដ៏ធំ និងគួរឲ្យស្ញប់ស្ញែងនោះទេ ប៉ុន្តែតាមរយៈទង្វើដ៏សាមញ្ញនៃចិត្តសន្ដោស និងការបម្រើ ។

មានរបៀប និងកាលៈទេសៈផ្សេងៗជាច្រើន ដែលយើងអាចបម្រើ និងស្រឡាញ់អ្នកដទៃ ។ សូមឲ្យខ្ញុំផ្ដល់យោបល់មួយចំនួន ៖

ទីមួយ សប្បុរសចាប់ផ្ដើមនៅក្នុងផ្ទះ ។ គោលការណ៍ដ៏សំខាន់បំផុតមួយ ដែលគួរតែអភិបាលគ្រប់ផ្ទះ គឺត្រូវអនុវត្តច្បាប់មាស---ដែលព្រះអម្ចាស់បានទូន្មានថា « អស់ទាំងការណ៍អ្វី ដែលអ្នករាល់គ្នាចង់ឲ្យមនុស្សលោកប្រព្រឹត្តនឹងខ្លួន នោះត្រូវឲ្យអ្នកប្រព្រឹត្តនឹងគេដូច្នោះដែរ » ( ម៉ាថាយ 7:12 ) ។ សូមធ្វើការ

ស្រមៃមើលមួយភ្លែត ថាតើអ្នកនឹងមានអារម្មណ៍យ៉ាងណា បើសិនអ្នកស្ថិតនៅចុងបញ្ចប់នៃការទទួលនូវពាក្យសម្ដី ឬអំពើដែលគ្មានការពិចារណានោះ ។ ដោយគំរូរបស់យើង នោះចូរយើងបង្រៀនសមាជិកគ្រួសារយើងឲ្យស្រឡាញ់គ្នាទៅវិញទៅមក ។

កន្លែងមួយទៀតដែលយើងមានឱកាសច្រើន ក្នុងការបម្រើនោះគឺនៅក្នុងសាសនាចក្រ ។ វួដ និងសាខាទាំងឡាយរបស់យើង គួរតែជាកន្លែងមួយដែលច្បាប់មាស តែងតែដឹកនាំពាក្យសម្ដី និងអំពើរបស់យើងទៅកាន់អ្នកផ្សេងទៀត ។ ដោយការប្រព្រឹត្តិល្អចំពោះគ្នាទៅវិញទៅមក និយាយពាក្យសម្ដីនៃការគាំទ្រ និងលើកទឹកចិត្ត ហើយយល់ពីតម្រូវការរបស់គ្នាទៅវិញទៅមក នោះយើងអាចជួយបង្កើតនូវសាមគ្គីនៃក្ដីស្រឡាញ់ក្នុងចំណោមសមាជិកវួដរបស់យើង ។ ទីណាដែលមានសេចក្ដីសប្បុរស ទីនោះគ្មានកន្លែងសម្រាប់ការនិយាយដើម ឬពាក្យសម្ដីគ្រោតគ្រាតនោះទេ ។

សមាជិកវួដ ទាំងពេញវ័យ និងយុវវ័យ អាចរួមគ្នាក្នុងការបម្រើប្រកបដោយអត្ថន័យ ដើម្បីផ្ដល់ពរជ័យដល់ជីវិតដទៃជាច្រើន ។ កាលពីពីរសប្ដាហ៍មុនប៉ុណ្ណោះ ប្រធានប្រចាំតំបន់អាមេរិកពាយព្យប៉ែកខាងត្បូង អែលឌើរ ណាស្ស បានរាយការណ៍ថា ដោយការចាត់តាំង « អ្នកខ្លាំងនៅក្នុងវិញ្ញាណ ទៅកាន់ពួកអ្នកដែលខ្សោយ » នោះពួកគេបានសង្គ្រោះដល់សមាជិកពេញវ័យ និងយុវវ័យរាប់រយនាក់ ។ តាមរយៈក្ដីស្រឡាញ់ និងការបម្រើ --- « ម្ដងមួយម្ដងមួយ » នោះពួកគេបានត្រឡប់មកវិញ ។ ទង្វើដ៏ល្អទាំងនេះបង្កើតនូវចំណងដ៏រឹងមាំ និងយូរអង្វែង រវាងអ្នកដែលចូលរួមគ្រប់ៗគ្នា ---ទាំងអ្នកជួយ និងអ្នកទទួលជំនួយ ។ មានអនុស្សាវរីយ៍ដ៏មានតម្លៃជាច្រើនដែលមកពីប្រភពនៃការបម្រើបែបនេះ ។

ពេលដែលខ្ញុំគិតត្រឡប់ពីការបម្រើសាសនាចក្ររយៈពេល 42 ឆ្នាំរបស់ខ្ញុំ អនុស្សាវរីយ៍ដ៏វិសេសបំផុតមួយចំនួន គឺពេលវេលាដែលខ្ញុំបានចូលរួមជាមួយសមាជិកវួដផ្សេងទៀត ក្នុងការផ្ដល់ការបម្រើដល់អ្នកដែលត្រូវការជំនួយ ។

ឧទាហរណ៍ ខ្ញុំចាំថា កាលជាប៊ីស្សពម្នាក់ ដោយធ្វើការជាមួយសមាជិកវួដមួយចំនួនក្នុងវួដរបស់ខ្ញុំ យើងបានសម្អាតក្រឡុកផ្ទុកអាហារសម្រាប់សត្វ នៅកសិដ្ឋានសុខុមាលភាពរបស់ស្ដេក ។ វាមិនមែនជាការងារដ៏គួរឲ្យសប្បាយនោះទេ ! បងប្រុសដែលមិនសូវសកម្មម្នាក់ ដែលមិនបានមកព្រះវិហារជាច្រើនឆ្នាំមកហើយនោះ ត្រូវបានអញ្ជើញឲ្យចូលរួមជាមួយយើង ។ ដោយសារតែក្ដីស្រឡាញ់ និងការរាក់ទាក់ដែលគាត់បានទទួលពីយើង កាលដែលយើងបានជជែកគ្នាដោយខ្លួនស្អុយពីក្រឡុកដាក់ស្មៅនោះ គាត់បានវិលត្រឡប់មកព្រះវិហារវិញ ហើយក្រោយមកបានផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធជាមួយភរិយានិងកូនៗគាត់ ។ ការរាក់ទាក់យើងតាមរយៈការបម្រើ បានផ្ដល់ពរជ័យដល់កូនៗ ចៅៗ និងឥឡូវនេះចៅៗទួតរបស់គាត់ទៀត ។ ពួកគេជាច្រើនបានបម្រើបេសកកម្ម រៀបការក្នុងព្រះវិហារបរិសុទ្ធ និងកំពុងចិញ្ចឹមគ្រួសារអស់កល្ប---កិច្ចការអស្ចារ្យកើតមកពីកិច្ចការដ៏តូច---ជាបំណែកមាសតូចៗនោះឯង ។

កន្លែងទីបី ដែលយើងអាចបម្រើ គឺក្នុងសហគមន៍របស់យើង ។ ដោយការបង្ហាញក្ដីស្រឡាញ់ដ៏បរិសុទ្ធនិងការខ្វល់ខ្វាយរបស់យើង នោះយើងអាចឈោងទៅជួយពួកអ្នកដែលត្រូវការជំនួយពីយើង ។ អ្នករាល់គ្នាជាច្រើន បានពាក់អាវ « ដៃដ៏ជាជំនួយ » និងបានធ្វើការដោយគ្មាននឿយហត់ ដើម្បីសម្រាលទុក្ខលំបាក និងអភិវឌ្ឍសហគមន៍របស់អ្នក ។ មជ្ឈិមវ័យវ័យក្មេងនៅស្ដេក សេនដៃ ប្រទេសជប៉ុន ថ្មីៗនេះបានផ្ដល់ការបម្រើក្នុងការស្វែងរកសមាជិកបន្ទាប់ពីការរញ្ជួយដី និងព្យុះស៊ូណាមិ ដ៏ហិនហោចនោះ ។ មានរបៀបច្រើនរាប់មិនអស់ដែលយើងអាចធ្វើការបម្រើ ។

តាមរយៈចិត្តសន្ដោស និងការបម្រើដោយអស់ពីចិត្តរបស់យើង នោះយើងអាចបង្កើតមិត្តភាពជាមួយនឹងអ្នកដែលយើងបម្រើ ។ ពីមិត្តភាពទាំងនេះ នោះនឹងមាននូវការយល់កាន់តែច្បាស់ពីការឧទ្ទិសយើងចំពោះដំណឹងល្អ និងបំណងប្រាថ្នារបស់យើង ដើម្បីរៀនបន្ថែមទៀតពីសាសនាចក្រ ។

មិត្តល្អរបស់ខ្ញុំ អែលឌើរ យ៉ូសែប វ៊ីតលីន ដ៏ចំណាស់ បានមានប្រសាសន៍ពីអំណាចនៃគោលការណ៍នេះថា ៖« ចិត្តសណ្ដោស គឺជាការចាំបាច់នៃភាពអស្ចារ្យ...[ វា ] គឺជាលិខិតឆ្លងដែន ដែលបើកទ្វារ និងបង្កើតមិត្តភាព ។ វាបន្ទន់ដួងចិត្ត និងបង្កើតទំនាក់ទំនង ដែលអាចនៅរហូតក្នុងឆាកជីវិត » ( « The Virtue of Kindness » *Ensign* ខែ ឧសភា ឆ្នាំ 2005 ទំព័រ 26) ។

របៀបមួយទៀតដែលយើងអាចបម្រើបុត្រាបុត្រីព្រះវរបិតា គឺតាមរយៈការបម្រើជាអ្នកផ្សព្វផ្សាយសាសនា---មិនគ្រាន់តែជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងនោះទេ ប៉ុន្តែជាមិត្ត និងអ្នកជិតខាងផងដែរ ។ ការលូតលាស់នៅអនាគតនៃសាសនាចក្រ នឹងមិនកើតឡើងគ្រាន់តែតាមរយៈការគោះលើទ្វារមនុស្សដែលយើងមិនស្គាល់នោះទេ ។ វានឹងកើតឡើង ពេលដែលសមាជិក ជាមួយនឹងអ្នកផ្សព្វផ្សាយសាសនា ពេញដោយសេចក្ដីស្រឡាញ់នៃព្រះ និងព្រះគ្រីស្ទមើលឃើញពីតម្រូវការ ហើយឆ្លើយតបចំពោះតម្រូវការទាំងនោះ ក្នុងវិញ្ញាណនៃការបម្រើដ៏សប្បុរស ។

បងប្អូនប្រុសស្រី កាលដែលយើងធ្វើដូចនេះ នោះអ្នកដែលមានដួងចិត្តស្មោះត្រង់ នឹងទទួលអារម្មណ៍នៃភាពស្មោះត្រង់ និងក្ដីស្រឡាញ់របស់យើង ។ មនុស្សជាច្រើននឹងចង់ដឹងបន្ថែមទៀតពីយើង ។ មានតែក្រោយពីការធ្វើការណ៍នេះប៉ុណ្ណោះ ទើបធ្វើឲ្យសាសនាចក្ររីកដុះដាល និងទៅពាសពេញផែនដី ។ ការណ៍នេះមិនអាចបានសម្រេច ដោយអ្នកផ្សព្វ ផ្សាយសាសនាប៉ុណ្ណោះទេ ប៉ុន្តែតម្រូវឲ្យមានចំណាប់អារម្មណ៍ និងការបម្រើពីសមាជិកគ្រប់រូបផងដែរ ។

ក្នុងគ្រប់ការបម្រើ យើងត្រូវស្គាល់ការបំផុសពីព្រះវិញ្ញាណបរិសុទ្ធ ។ ស -ម្លេងដ៏តូចរហៀង នឹងឲ្យយើងដឹងថានរណាដែលត្រូវការជំនួយរបស់យើង និងពីអ្វីដែលយើងអាចធ្វើដើម្បីជួយពួកគេបាន ។

ប្រធាន ស្ពែនស៊ើរ ដបុលយូ឴ ឃឹមបឹល បានមានប្រសាសន៍ថា ៖ « វាសំខាន់ណាស់ ថាយើងបម្រើគ្នាទៅវិញទៅមកនៅក្នុងនគរ... ញឹកញាប់ណាស់ ទង្វើនៃការបម្រើរបស់យើងមាននូវការលើកទឹកចិត្ត ឬការផ្ដល់ឲ្យដ៏សាមញ្ញ ... ជួយដោយកិច្ចការដ៏សាមញ្ញ ប៉ុន្តែលទ្ធផលដ៏ប្រពៃអាចកើតឡើង...ពីកិច្ចការដ៏តូច ប៉ុន្តែដោយចេតនាពិត ! » ( « Small Acts of Service » *Ensign* ខែ ធ្នូ ឆ្នាំ 1974 ទំព័រ 2) ។

ហើយ ប្រធាន ថូម៉ាស អេស ម៉នសុន បានទូន្មានថា ៖ « តម្រូវការរបស់អ្នកដទៃតែងកើតមានជានិច្ច ហើយយើងម្នាក់ៗអាចធ្វើអ្វីមួយ ដើម្បីជួយដល់មនុស្សម្នាក់...លើកលែងតែយើងលះបង់ខ្លួនឯងក្នុងការបម្រើអ្នកដទៃ បើពុំនោះសោតទេ ជីវិតរបស់យើងមានគោលបំណងតិចតួចណាស់ » ( *Ensign* « What Have I Done for Someone Today ? » ខែ វិច្ឆកា ឆ្នាំ 2009 ទំព័រ 85) ។

បងប្អូនប្រុសស្រី សូមឲ្យខ្ញុំសង្កត់ជាថ្មីម្ដងទៀតថា លក្ខណៈដ៏សំខាន់បំផុតនៃព្រះវរបិតាសួគ៌ និងព្រះរាជបុត្រាជាទីស្រឡាញ់របស់ទ្រង់ ដែលយើងគួរប្រាថ្នា និងស្វែងរក ដើម្បីយើងអាចមានក្នុងខ្លួនយើងនោះ ជាអំណោយនៃសេចក្ដីសប្បុរស ដែលជាសេចក្ដីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ ។ ពីអំណោយនេះនោះយើងអាចអភិវឌ្ឍសមត្ថភាពរបស់យើងក្នុងការស្រឡាញ់ និងបម្រើអ្នកដទៃ---ដូចដែលព្រះអង្គសង្គ្រោះបានធ្វើ ។

ព្យាការី មរមន បានបង្រៀនយើងពីសារៈសំខាន់ដ៏ខ្ពស់បំផុតពីអំណោយនេះ ហើយបានប្រាប់យើងពីរបៀបដែលយើងអាចទទួលវា ៖

« ហេតុដូច្នេះហើយ ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ ចូរអធិស្ឋានដល់ព្រះវរបិតា ដោយអស់ពីកម្លាំងចិត្ត ដើម្បីឲ្យអ្នករាល់គ្នាបានពោរពេញ ដោយសេចក្ដីស្រឡាញ់នេះ ដែលទ្រង់បានប្រទានដល់អស់អ្នកណាដែលជាអ្នកដើរតាមដ៏ពិតនៃព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យអ្នករាល់គ្នាអាចក្លាយទៅជាកូនព្រះ ដើម្បីកាលណាទ្រង់នឹងលេចមក នោះយើងរាល់គ្នានឹងបានដូចជាទ្រង់ ត្បិតយើងនឹងឃើញទ្រង់ ជាទ្រង់ពិតប្រាកដ ដើម្បីឲ្យយើងអាចមានសង្ឃឹមនេះ ដើម្បីឲ្យយើងអាចបានបរិសុទ្ធដូចជាទ្រង់បរិសុទ្ធ » ( មរ៉ូណៃ 7:48 ) ។

ការណ៍ដ៏អស្ចារ្យសម្រេចបានតាមរយៈកិច្ចការដ៏តូច និងសាមញ្ញ ។ ដូចជាបំណែកមាសតូចៗ ដែលប្រមូលផ្ដុំយូរៗទៅក្លាយជាទ្រព្យសម្បត្តិដ៏ធំ នោះទង្វើតូចតាច និងសាមញ្ញ នៃចិត្តសន្ដោស និងការបម្រើ នឹងប្រមូលផ្ដុំជាជីវិតមួយដែលពេញដោយក្ដីស្រឡាញ់ដល់ព្រះវរបិតា ដែលជាការឧទ្ទិសដល់កិច្ចការនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងវិញ្ញាណនៃក្ដីសុខសាន្ត និងអំណរ រៀងរាល់ពេលដែលយើងឈោងទៅជួយម្នាក់ផ្សេងទៀត ។

កាលដែលយើងជិតឈានដល់រដូវបុណ្យនៃការរស់ឡើងវិញ នោះចូរយើងបង្ហាញក្ដីស្រឡាញ់ និងការដឹងគុណរបស់យើងចំពោះការលះបង់ដ៏ធួនរបស់ព្រះអង្គសង្គ្រោះ តាមរយៈទង្វើដ៏សាមញ្ញ និងសន្ដោសប្រណី ទៅកាន់បងប្អូនប្រុសស្រីយើងនៅផ្ទះ នៅសាសនាចក្រ និងក្នុងសហគមន៍របស់យើង ។ សម្រាប់ការណ៍នេះ ខ្ញុំអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។